ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

## គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

## (គធ.ខប)

## សម្រាប់

## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

# មាតិកា


**គោលបំណង** ........................................................................................ ១

**I.សមាសភាព រចនាសម្ព័ន្ធ ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប** .......... ២

១.សមាសភាព និងរចនាសម្ព័ន្ធរបស់ គធ.ខប ........................................................ ២

២. សមាសភាព គធ.ខប និងលេខាធិការដ្ឋាននៃ គធ.ខប ........................................ ៣

ក.អនុគណៈកម្មការរបស់ គធ.ខប ........................................................................ ៣

ខ.អនុគណៈកម្មការបច្ចេកទេស ........................................................................... ៣

គ.អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល .................................................... ៣

៣. ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប ...................................................... ៣

**II.ការសម្របសម្រួលការងារបញ្ចូល និងបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត**... ៥

**III.ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប** ........................................................................................ ៥

១.ទីតាំងនៃមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ............................ ៥

២.សន្តិសុខ និងសុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត .................... ៦

៣.ការគ្រប់គ្រងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ........................................ ៦

ក.ការអនុញ្ញាត ........................................................................................... ៦

ខ.បម្រាម .................................................................................................... ៧

៤.ក្រុមត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅ គធ.ខប ........................................... ៧

៥.ក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គធ.ខប .............................................. ៨

៦.ក្រុមសម្របសម្រួលនៅ គធ.ខប ....................................................................... ៨

**IV.ការប្រគល់ និងការទទួលកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្តឹង» និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គធ.ខប** ........................ ៨

១.ការប្រគល់ .................................................................................................. ៨

២.ការទទួល .................................................................................................... ៨

**V.ការដាក់ និងការទទួលពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គឃ.សប នៅ គធ.ខប** ........................................................................ ១០

១.អ្នកមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ ........ ១០
២.ការបំពេញពាក្យបណ្តឹង (ទ.១២០២) ........ ១០
៣.ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប ........ ១០
ក.ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ........ ១១
ខ.ពាក្យបណ្តឹងដែលបានទទួលនៅ គធ.ខប ក្រោយរយៈពេលកំណត់ ........ ១១
គ.ពាក្យបណ្តឹងដែលបានទទួលនៅ គធ.ខប ក្នុងរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់គ្រប់គ្រាន់ ........ ១១
**VI. ប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ........ ១២**
១.ការណែនាំក្រុមត្រួតពិនិត្យលទ្ធផល ........ ១២
២.ការកំណត់ និងការរៀបចំតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ........ ១២
៣.ការកំណត់ និងការរៀបចំបន្ទប់សម្រាប់ក្រុមត្រួតពិនិត្យលទ្ធផល ........ ១៣
**VII.ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ........ ១៣**
១.ដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ........ ១៤
២.ការពិនិត្យសម្រេចរបស់ គធ.ខប នៅលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងការប្រើប្រាស់ ........ ១៥
៣.ការរៀបចំសម្ភារ ឯកសារឡើងវិញ ........ ១៦
**VIII.ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ដាក់នៅ គឃ.សប និងនៅ គធ.ខប ........ ១៦**
១.ករណីគ្មានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬពុំមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ........ ១៦
២.ករណីមានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោត ........ ១៧
ក.នីតិវិធីនៃការបើកកញ្ចប់សុវត្ថិភាព «ក» ........ ១៧
ខ.របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ........ ១៨
គ.ឯកសារដែលត្រូវដាក់ជូន គធ.ខប ដើម្បីពិនិត្យសម្រេច ........ ១៩

ឃ.ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតឡើងវិញ ...... ១៩

៣.ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ...... ១៩

ក.ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ...... ២០

ខ.ប្រសិនបើ គធ.ខប សម្រេចយល់ព្រមកែតម្រូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ក្នុងករណីរកឃើញកំហុសឆ្គងក្នុងការគណនាតួលេខ ...... ២១

គ.ប្រសិនបើ គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ...... ២២

៤.ការបញ្ជូន និងការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតក្នុងឃុំ សង្កាត់ដែល គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ...... ២៤

ក.ការបញ្ជូន ...... ២៤

ខ.ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោត ...... ២៤

គ.លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ...... ២៥

**IX.ការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត** ...... ២៦

១.ការរៀបចំ និងការទុកដាក់កម្មវិធីបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ...... ២៦

២.ការផ្ទៀងផ្ទាត់ឡើងវិញ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ...... ២៦

៣.ការបំពេញ និងការប្រើប្រាស់ទម្រង់បែបបទនៅ គធ.ខប ...... ២៧

ក.តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ...... ២៧

ខ.កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ...... ២៨

គ.ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ...... ២៨

**X.ការវេចខ្ចប់ និងការបញ្ជូនលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងរាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប** ...... ២៩

១.ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ណាដែល គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ...... ២៩

២.ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ណាដែល គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ...... ២៩

ក.ការវេចខ្ចប់កញ្ចប់ «យ ពិសេស» ...... ៣០

ខ.ការវេចខ្ចប់ស្បោង «យ» នៃឃុំ សង្កាត់ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ...... ៣១

គ.ការវេចខ្ចប់ស្បោង «ឃ មានពាក្យបណ្ដឹង» ........................................ ៣២

ឃ.ការបញ្ជូន និងការប្រគល់ ទទួល........................................ ៣៣

ង.ការវេចខ្ចប់សម្ភារ ឯកសារនៅសល់បញ្ជូនទៅ គ.ជ.ប........................................ ៣៣

**ទម្រង់បែបបទសម្រាប់ប្រើប្រាស់នៅ គធ.ខប** ........................................ ៣៤

# អក្សរកាត់

| | | |
|---|---|---|
| ១. | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៣. | លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ៤. | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| ៥. | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| ៦. | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៧. | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ៨. | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ប.ន.ត.រ |
| ៩. | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១០. | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |
| ១១. | ទម្រង់បែបបទលេខ | ទ. |

# គោលបំណង

ដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នាថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ប្រព្រឹត្តទៅបានដោយរលូន តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ត.រ) និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ប.ន.ត.រ) គ.ជ.ប បានរៀបចំចងក្រងសៀវភៅណែនាំ គធ.ខប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះឡើង ដើម្បីជាជំនួយ និងលើកកម្ពស់ការយល់ដឹងដល់ គធ.ខប អំពីការទទួលខុសត្រូវលើភារកិច្ចដ៏ច្រើនដែលច្បាប់បោះឆ្នោតអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ឬដែល គ.ជ.ប បានកំណត់ក្នុង ប.ន.ត.រ ជាពិសេសអំពី៖

- ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្រោមសមត្ថកិច្ចរបស់ខ្លួន
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងនៅ គធ.ខប
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានពាក្យបណ្តឹងនៅ គធ.ខប
- ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតបញ្ជូនមក គ.ជ.ប ករណី គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់
- ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតបញ្ជូនមក គ.ជ.ប ករណី គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់។

គ.ជ.ប សង្ឃឹមថា គធ.ខប នឹងយកចិត្តទុកដាក់សិក្សាស្វែងយល់ និងអនុវត្តតាមការណែនាំក្នុងសៀវភៅនេះ ដើម្បីសម្រេចភារកិច្ចបានត្រឹមត្រូវ ទាន់ពេលវេលា និងមានតម្លាភាព។

# គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប)

## I. សមាសភាព រចនាសម្ព័ន្ធ ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប

### ១. សមាសភាព និងរចនាសម្ព័ន្ធរបស់ គធ.ខប

គធ.ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលបង្កើតឡើងដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន។

រចនាសម្ព័ន្ធរបស់ គធ.ខប




**១.លគធ.ខប**

| | |
|---|---|
| -ប្រធាន | ១រូប |
| -អនុប្រធាន | ១រូប |
| -សមាជិក | ៣រូប |

**២.អនុគណៈកម្មការបច្ចេកទេស**

- ប្រធាន លគធ.ខប ជាប្រធាន
- អនុប្រធាន លគធ.ខប ជាអនុប្រធាន
- សមាជិក គធ.ខប ជាប្រធានផ្នែកនីមួយៗ
- សមាជិកលគធ.ខបជាអនុប្រធានផ្នែកនីមួយៗ
- អនុប្រធានផ្នែក លគធ.ខប ជាអនុប្រធាននៃផ្នែកនីមួយៗ
- អនុប្រធានផ្នែកនៃ គធ.ខប ទទួលបន្ទុកការងារភស្តុភាជាអនុប្រធានផ្នែក។

**៣.អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល**

- ប្រធាន គធ.ខប ជាប្រធាន
- អនុប្រធាន គធ.ខប ជាអនុប្រធាន
- ប្រធាន និងអនុប្រធាន លគធ.ខប ជាសមាជិក

#### ភារកិច្ចប្រធាន លគធ.ខប

ទទួលខុសត្រូវគ្រប់គ្រងការងារហិរញ្ញវត្ថុ អគារ រថយន្ត និងសម្ភារបរិក្ខារទាំងអស់របស់ គធ.ខប និងចុះហត្ថលេខាលើលិខិតស្នាមពាក់ព័ន្ធនឹងការងារទាំងអស់នេះ ហើយស្នើសុំយោបល់សម្រេចពីប្រធាន គធ.ខប។

#### ភារកិច្ចប្រធានអនុគណៈកម្មការបច្ចេកទេស

- ធានាថា សមាជិក សមាជិកានៃអនុគណៈកម្មការបច្ចេកទេសទាំងអស់ត្រូវបំពេញភារកិច្ចតាមផ្នែកនីមួយៗដែលខ្លួនទទួលខុសត្រូវ
- ចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្ដីសម្រេចរបស់ គធ.ខប
- ចុះហត្ថលេខាគ្រប់ឯកសារផ្លូវការរបស់អនុគណៈកម្មការបច្ចេកទេស។

## ២. សមាសភាព គធ.ខប និងលេខាធិការដ្ឋាននៃ គធ.ខប

គធ.ខប ត្រូវមានសមាសភាពចំនួន ៧រូប ដែលមានប្រធាន ១រូប អនុប្រធាន ១រូប និងសមាជិក ៥រូប មានលេខាធិការដ្ឋានមួយជាជំនួយការ និងមានអនុគណៈកម្មការបច្ចេកទេស ដែលមានផ្នែកជំនាញចំនួន ៥ ដែលត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួនដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.ត.រ។

### ក. អនុគណៈកម្មការរបស់ គធ.ខប

គធ.ខប មានអនុគណៈកម្មការដូចខាងក្រោម៖

- អនុគណៈកម្មការបច្ចេកទេស
- អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល
- អនុគណៈកម្មការផ្សេងៗទៀតតាមការចាំបាច់

អនុគណៈកម្មការខាងលើនេះត្រូវសម្រេច និងតែងតាំងដោយ គធ.ខប។

### ខ.អនុគណៈកម្មការបច្ចេកទេស

អនុគណៈកម្មការបច្ចេកទេស មានសមាសភាពដូចខាងក្រោម៖

- ប្រធាន លគធ.ខប ជាប្រធាន
- អនុប្រធាន លគធ.ខប ជាអនុប្រធាន
- សមាជិក គធ.ខប ជាប្រធានផ្នែកនីមួយៗ
- សមាជិក លគធ.ខប ដែលជាប្រធានផ្នែកនីមួយៗ នៃ លគធ.ខប ជាអនុប្រធានផ្នែក
- អនុប្រធានផ្នែកនីមួយៗ នៃ លគធ.ខប ជាអនុប្រធានផ្នែក
- អនុប្រធានផ្នែកជំនាញនៃ គធ.ខប ទទួលបន្ទុកការងារភស្តុភារ ជាអនុប្រធានផ្នែក

អនុគណៈកម្មការបច្ចេកទេសមានជំនាញផ្នែកទាំង ៥ (ប្រាំ) របស់ គធ.ខប សម្រាប់អនុវត្តការងារបច្ចេកទេសទាក់ទងនឹងការបោះឆ្នោត។

### គ.អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល

អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល មានសមាសភាព៖

| | |
|---|---|
| - ប្រធាន គធ.ខប | ជាប្រធាន |
| - អនុប្រធាន គធ.ខប | ជាអនុប្រធាន |
| - ប្រធាន អនុប្រធាន លគធ.ខប | ជាសមាជិក |

អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួលមានផ្នែកពាក់ព័ន្ធទាំង ៥ (ប្រាំ) ជាជំនួយការ។

## ៣. ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប

គធ.ខប ត្រូវមានការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅឃុំ សង្កាត់ ក្នុងរាជធានី ខេត្តរបស់ខ្លួនតាមការប្រគល់សិទ្ធិអំណាចនិងត្រួតពិនិត្យនីត្យានុកូលភាពដោយគ.ជ.ប។

គធ.ខប ត្រូវ៖

- ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមរយៈការបោះឆ្នោតជាសម្ងាត់
- គោរព និងអនុវត្តផែនការមេ និងប្រតិទិននៃការបោះឆ្នោត គ្រប់គ្រងថវិការបស់ខ្លួន ចុះបញ្ជី និងថែរក្សាបញ្ជីសារពើភ័ណ្ឌនៃសម្ភារ បរិក្ខារ សម្រាប់ការបោះឆ្នោត
- គោរព និងអនុវត្តច្បាប់ បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងគោលការណ៍ណែនាំរបស់ គ.ជ.ប និងក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត
- ចាត់វិធានការពាក់ព័ន្ធទៅនឹងកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងដំណើរការបោះឆ្នោត
- តាមដានត្រួតពិនិត្យការងារគ្រប់គ្រង និងប្រតិបត្តិការរបស់ គឃ.សប
- បែងចែកសម្ភារ បរិក្ខារបោះឆ្នោតជូន គឃ.សប
- ចែកចាយរាល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត
- លើកគម្រោង និងអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីការបោះឆ្នោតក្នុងក្របខណ្ឌរាជធានី ខេត្តដោយយោងតាមការណែនាំរបស់ គ.ជ.ប
- លើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីដំណើរការបោះឆ្នោតដោយធ្វើការសម្របសម្រួលការងារអប់រំអ្នកបោះឆ្នោតនៅក្នុងក្របខ័ណ្ឌរាជធានី ខេត្តដោយសហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាលនានា
- អនុវត្តការងារទាក់ទងនឹងបច្ចេកទេស ការអនុវត្តទំនើបកម្មបច្ចេកវិទ្យាព័ត៌មានក្នុងដំណើរការគ្រប់គ្រងការងាររដ្ឋបាល និងការបោះឆ្នោត
- សម្របសម្រួល និងត្រួតពិនិត្យការឃោសនាបោះឆ្នោតនៅក្នុងរាជធានី ខេត្ត
- ចាត់គ្រប់វិធានការ ដើម្បីធានាឱ្យមានភាពស្មើគ្នាក្នុងការប្រើប្រាស់អគារ ឬទីសាធារណៈដល់គណបក្សនយោបាយឈរឈ្មោះក្នុងអំឡុងពេលឃោសនាបោះឆ្នោត
- ដំណើរការកម្មវិធីផ្សព្វផ្សាយព័ត៌មាន
- លើកសំណើសុំ គ.ជ.ប តែងតាំងសមាសភាព គឃ.សប និង គ.ក.ប ក្នុងរាជធានី ខេត្ត និងធ្វើតារាងប្រាក់កម្រៃសម្រាប់សមាជិក និងមន្ត្រីនៃ គធ.ខប គឃ.សប និង គ.ក.ប តាមការណែនាំរបស់ គ.ជ.ប
- តាមដានការងារគ្រប់គ្រង និងចាត់ចែងរបស់ គឃ.សប ក្នុងការបូកសរុបលទ្ធផលបណ្តោះអាសន្នពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន
- រៀបចំចាត់ចែងប្រមូល និងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន ប្រកាសលទ្ធផលបណ្តោះអាសន្នតាមឃុំ សង្កាត់ កំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត
- រៀបចំវេចខ្ចប់ និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ព្រមទាំងសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោតពាក់ព័ន្ធក្នុងរាជធានី ខេត្តរបស់ខ្លួនជូនទៅ គ.ជ.ប

- ទទួលពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ និងដំណើរការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់
- ដោះស្រាយរាល់វិវាទកម្មក្រោមសមត្ថកិច្ចរបស់ខ្លួន ដូចដែលបានណែនាំដោយ គ.ជ.ប
- ចាត់គ្រប់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត
- សហការចាត់ចែងការងារសន្តិសុខបោះឆ្នោតនៅក្នុងរាជធានី ខេត្ត
- ជូនយោបល់ដល់ គ.ជ.ប អំពីបរិយាកាសក្នុងរាជធានី ខេត្ត ដើម្បីចាត់វិធានការនានា ធានាឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងមានតម្លាភាព
- វាយតម្លៃអំពីប្រសិទ្ធភាពការងាររបស់សមាជិកទាំងឡាយនៃ គឃ.សប
- អនុវត្តការងារដទៃទៀត ឬអនុវត្តសិទ្ធិអំណាចដទៃទៀត ដែលត្រូវបានប្រគល់ឱ្យដោយ គ.ជ.ប។

**ចំណាំ៖** ភារកិច្ចរបស់ប្រធាន អនុប្រធាន សមាជិក គធ.ខប និងភារកិច្ចរបស់ប្រធាន អនុប្រធាន និងសមាជិក លគធ.ខប មានចែងលម្អិតនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

## II. ការសម្របសម្រួលការងារបញ្ចូល និងបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត

គធ.ខប មានភារកិច្ចផ្ដល់ការគាំទ្រដល់ គឃ.សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបឋមនៃការបោះឆ្នោតឱ្យបានទាន់ពេលវេលានៅល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត ដើម្បីបញ្ជូនទិន្នន័យតាមអ៊ីនធឺណិតមក គ.ជ.ប ធ្វើការផ្សព្វផ្សាយជូនដល់សាធារណជន និងភាគីពាក់ព័ន្ធ។ ក្នុងដំណើរការនេះ គធ.ខប ត្រូវតាមដានការបញ្ជូនរូបភាព និងទិន្នន័យកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយ គឃ.សប។ ប្រសិនបើពិនិត្យឃើញថា គឃ.សប មានការយឺតយ៉ាវ ឬមិនទាន់បានបញ្ជូនទិន្នន័យមក គ.ជ.ប ទេ គធ.ខប ត្រូវទំនាក់ទំនង និងណែនាំរំឭកដល់ គឃ.សប ពាក់ព័ន្ធឱ្យចាត់ចែងបញ្ជូនមក គ.ជ.ប ឱ្យទាន់ពេលវេលា។

## III. ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន តាមប្រមាណវិធីដោយដៃ និងតាមកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោតកំណត់ដោយ គ.ជ.ប ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យសម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ។

### ១. ទីតាំងនៃមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប

មជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត អាចមានទីតាំងនៅ លគធ.ខប ឬនៅអគារមួយផ្សេង ឬផ្នែកណាមួយដែលមានទំហំទូលាយល្មមអាចរៀបចំឱ្យមានកន្លែងបម្រុង ដូចខាងក្រោម ៖

- កន្លែងសម្រាប់ទទួលកញ្ចប់ «គ ពិសេស» និងស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្ដឹង» និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ពីគ្រប់ឃុំ សង្កាត់ក្នុងរាជធានី ខេត្តពាក់ព័ន្ធ ដែលត្រូវស្ថិតនៅក្បែរផ្លូវចូល

- បន្ទប់មួយទូលាយល្មមដែលអាចស្តុកកញ្ចប់ «គ ពិសេស» និងស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្តឹង» ដាច់ដោយឡែកពីគ្នាទៅតាមឃុំ សង្កាត់ និងមានសរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗផង
- បន្ទប់មួយដោយឡែកដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែល គឃ.សប បានប្រគល់ឱ្យ
- បន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើន ដែលត្រូវមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើក្នុងពេលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ហើយដែលអាចទទួលបានទាំងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ទាំងតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ ទាំងអ្នកប្តឹងពាក់ព័ន្ធ ឬតំណាង
- បន្ទប់ស្អាតតូចមួយ (ប្រសិនបើមាន) សម្រាប់ដាក់គ្រឿងបរិក្ខារកុំព្យូទ័រ ដែលមានភ្ជាប់អ៊ីនធឺណិត និងមានបំពាក់កម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត ដែលរៀបចំ និងផ្តល់ជូនដោយ គ.ជ.ប។

**២. សន្តិសុខ និងសុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត**

គធ.ខប ត្រូវធានាអំពីសន្តិសុខ សុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។ នៅក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត គធ.ខប ត្រូវចាត់ចែងដូចខាងក្រោម៖

- ត្រូវចាត់ឱ្យមានមន្ត្រីម្នាក់ទទួលបន្ទុកសណ្តាប់ធ្នាប់ក្នុងមជ្ឈមណ្ឌល និងត្រូវមានមន្ត្រីម្នាក់ប្រចាំការនៅមាត់ទ្វារចេញចូល ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន គធ.ខប
- ត្រូវបិទទ្វារ និងបង្អួចទាំងអស់ និងចាក់សោយ៉ាងត្រឹមត្រូវ នៅពេលផុតម៉ោងធ្វើការងារ
- ត្រូវស្នើសុំកិច្ចសហការពីគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់កម្លាំងការពារនៅបរិវេណខាងក្រៅ
- ត្រូវរៀបចំចាត់កម្លាំងសន្តិសុខផ្ទាល់របស់ គធ.ខប ដើម្បីការពារបរិវេណខាងក្នុង។

**៣. ការគ្រប់គ្រងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត**

គធ.ខប ត្រូវទទួលបន្ទុកគ្រប់គ្រងការចេញចូលមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប និងមានសិទ្ធិអំណាចចេញ ចូលមជ្ឈមណ្ឌលនេះ។

ជនគ្រប់រូបដែលមានវត្តមាននៅក្នុងបរិវេណសន្តិសុខ និងក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គធ.ខប។

**ក. ការអនុញ្ញាត**

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងមជ្ឈមណ្ឌលនេះនូវជនទាំងឡាយ ដូចខាងក្រោម៖

-ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដែលបានទទួលការ ចាត់តាំង

-តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកយកព័ត៌មាន និងអ្នកប្តឹង ឬតំណាង

-ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន គធ.ខប ឬតំណាង គធ.ខប សំណូមពរក្នុងករណីចាំបាច់

-មន្ត្រីនៃ គ.ជ.ប ដែលកំពុងបំពេញភារកិច្ចស៊ើបអង្កេតអំពើល្មើស ដែលគេបានចោទប្រកាន់ចំពោះសមាជិក ឬមន្ត្រីនៃ គធ.ខប ដែលចាត់ឱ្យជួយក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។

ខ. បម្រាម

ហាមជនគ្រប់រូបចូលក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ៖

- ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជននៃបញ្ជីណាម្នាក់
- ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃ គធ.ខប បំពេញចិត្ត ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

**៤. ក្រុមត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅ គធ.ខប**

គធ.ខប ត្រូវតែងតាំងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប មួយក្រុម ឬច្រើនក្រុម ដោយយោងតាមចំនួនតិច ឬច្រើននៃឃុំ សង្កាត់ ក្នុងរាជធានី ខេត្តនីមួយៗ ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងចាត់តាំងមួយក្រុមផ្សេងទៀត ដើម្បីបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន។

ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗដែលត្រូវបានតែងតាំង អាចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ចំនួនតិចជាង ១០ ឬច្រើនជាង ១០ និងអាចបែងចែកឱ្យទទួលបន្ទុកឃុំ សង្កាត់ ក្នុងក្រុង ស្រុក ខណ្ឌមួយ ឬលើសពីមួយ។

សមាសភាពនៃក្រុមត្រួតពិនិត្យលទ្ធផល ត្រូវចាត់តាំងពីក្នុងចំណោមសមាសភាពអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប និងមន្ត្រីនៃ លគធ.ខប ក្នុងនោះត្រូវយកចិត្តទុកដាក់ចំពោះមន្ត្រីណាដែលពេលនោះ មិនសូវមានការងារមមាញឹក ដូចជាគ្រូបង្ហាត់ជាដើម។ គធ.ខប អាចលើកសំណើសុំតែងតាំងសមាជិកនៃ គឃ.សប ដែលស្ថិតនៅជិត លគធ.ខប បញ្ចូលក្នុងក្រុមត្រួតពិនិត្យលទ្ធផល ក្នុងករណីពុំមានមន្ត្រីបុគ្គលិក គ្រប់គ្រាន់។

ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ មានសមាសភាពចំនួន ៤រូប ដូចខាងក្រោម៖

- ប្រធាន ១រូប ដែលជាសមាជិក គធ.ខប ឬមន្ត្រី នៃ លគធ.ខប
- អនុប្រធាន ១រូប
- លេខាធិការ ១រូប
- ជំនួយការ ១រូប។

ក្រុមត្រួតពិនិត្យលទ្ធផល មានភារកិច្ចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ តាមចំនួនឃុំ សង្កាត់ ដែលក្រុមទទួលបន្ទុកប៉ុណ្ណោះ។

៥. ក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គធ.ខប

ប្រធាន លគធ.ខប ត្រូវទទួលបន្ទុកដឹកនាំក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តដោយផ្ទាល់។ ក្រុមបូកសរុបលទ្ធផល មានសមាសភាព ដូចខាងក្រោម៖

- សមាជិក គធ.ខប ដែលជាប្រធានផ្នែករដ្ឋបាល ១រូប
- សមាជិក គធ.ខប ដែលជាប្រធានផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេស ១រូប
- មន្ត្រីចេះប្រើប្រាស់កុំព្យូទ័រ មួយចំនួនតាមការចាំបាច់
- ការីកុំព្យូទ័រ ឬមន្ត្រីដែលមានចំណេះដឹងខាងការប្រើប្រាស់កុំព្យូទ័រ ១រូប។

៦. ក្រុមសម្របសម្រួលនៅ គធ.ខប

ក្រុមសម្របសម្រួលនៅ គធ.ខប មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - ប្រធាន លគធ.ខប | ប្រធាន |
| - សមាជិក គធ.ខប ដែលជាប្រធានផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេស | អនុប្រធាន |
| - សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត | សមាជិក |
| - ជំនួយការបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត ព័ត៌មាន និង ទំនាក់ទំនងសាធារណៈ (គ្រូបង្គោល) | សមាជិក |
| - មន្ត្រីប្រតិបត្តិការ និងភស្តុភារ | សមាជិក |
| - លេខាធិការ | សមាជិក |

សមាសភាពជាក់ស្តែងត្រូវចាត់តាំងតាមរយៈលិខិតបង្គាប់ការរបស់ គធ.ខប។

## IV. ការប្រគល់ និងការទទួលកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្តឹង» និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គធ.ខប

១. ការប្រគល់

នៅពេលមកដល់មជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ភ្លាម ប្រធាន គឃ.សប ត្រូវប្រគល់ទៅឱ្យមន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារនៃ គធ.ខប នូវ៖

- កញ្ចប់ «គ ពិសេស» រាល់ស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្តឹង» និងរាល់កញ្ចប់ដែលមានវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត
- លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ពាក់ព័ន្ធ។

២. ការទទួល

ដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដែលប្រធាន គឃ.សប បានប្រគល់ឱ្យ មន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារត្រូវ៖

- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ នូវកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្ដឹង» ទាំងអស់ និងស្បោងសម្ភារ ឯកសារផ្សេងៗទៀត ដោយផ្អែកលើ ទ.១១០៧ ដែលមានក្នុងកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្ដឹង» ក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ ឬស្បោងទាំងនោះ និងដែលប្រធាន គឃ.សប បានប្រគល់ជូន
- ចុះហត្ថលេខាលើ ទ.១១០៧ ពាក់ព័ន្ធ ដោយបញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ (ប្រសិនបើត្រួតពិនិត្យឃើញថាត្រឹមត្រូវហើយ)
- កត់ត្រាមុខសម្ភារ ឯកសារដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីទទួលសម្ភារ ឯកសាររបស់ខ្លួន ដោយត្រូវចារថា «ការប្រគល់គ្រប់ចំនួន»។ ប្រសិនបើមានស្បោង «គ» ណាមួយ ឬច្រើន មានសរសេរសម្គាល់ថា «មានពាក្យបណ្ដឹង» ត្រូវចារបន្ថែមក្នុងបញ្ជីទទួលសម្ភារ ឯកសាររបស់ខ្លួនថា «មានពាក្យបណ្ដឹង» និងត្រូវ៖
  - ស្រង់កត់ត្រាឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់
  - យកកញ្ចប់ «គ ពិសេស» និងស្បោង «គ» ដែលមានសរសេរសម្គាល់ថា «គ មានពាក្យបណ្ដឹង» នៃឃុំ សង្កាត់ពាក់ព័ន្ធ ទៅរក្សាទុកដោយឡែកនៅក្នុងបន្ទប់ស្តុក ដើម្បីងាយស្រួលរក
- ចាត់ចែងប្រើប្រាស់ ទ.១១០៧ ដែលបានចុះហត្ថលេខារួច ដូចខាងក្រោម៖

ទ.១១០៧ ចំនួន ៣ច្បាប់
- ១ច្បាប់ ជូនប្រធាន គឃ.សប វិញ
- ១ច្បាប់ រក្សាទុកជាឯកសារ
- ១ច្បាប់ ដាក់ចូលក្នុងហោប៉ៅក្រៅកញ្ចប់ «គ ពិសេស» ឬស្បោង «គ» ឬស្បោង «គ មានពាក្យបណ្ដឹង»ពាក់ព័ន្ធ

- ចាត់ចែង និងណែនាំសហការីរបស់ខ្លួនដែលទទួលបន្ទុករក្សាស្តុក ឱ្យ៖
  - នាំយកកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬស្បោង «គ មានពាក្យបណ្ដឹង» ទៅរក្សាទុកក្នុងបន្ទប់ស្តុកកញ្ចប់ «គ ពិសេស» និងស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្ដឹង»
  - នាំយកកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ទៅរក្សាទុកនៅក្នុងបន្ទប់មួយសម្រាប់រក្សាទុកសម្ភារ ឯកសារនៅសល់ ដែលបានត្រៀមទុកស្រាប់
  - បែងចែក និងរក្សាទុកមុខសម្ភារ ឯកសារដោយឡែកពីគ្នាតាមឃុំ សង្កាត់ ព្រមទាំងត្រូវសរសេរលេខកូដឃុំ សង្កាត់នីមួយៗផង។
- រាយការណ៍អំពីចំនួនកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្ដឹង» និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ដែលបានទទួលពីគ្រប់ឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ហើយត្រូវបញ្ជាក់ឱ្យច្បាស់នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្ដឹង ជូន គធ.ខប ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យត្រួតពិនិត្យលទ្ធផលទៅតាមករណីជាក់ស្តែងនីមួយៗ
- យកស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) តាមឃុំ សង្កាត់ ដើម្បីបញ្ជូនឱ្យប្រធាន គធ.ខប ចាត់ចែងបូកសរុបចំនួន

ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងរាជធានី ខេត្តរបស់ខ្លួនរួចបញ្ជូនទៅ គ.ជ.ប។

## V. ការដាក់ និងការទទួលពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គឃ.សប នៅ គធ.ខប

### ១. អ្នកមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់

ភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលទទួលបានការអនុញ្ញាតឱ្យសង្កេតមើលការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ណាមួយ ឬតំណាងដែលមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ គឃ.សប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គឃ.សប ទៅ គធ.ខប។

### ២. ការបំពេញពាក្យបណ្តឹង (ទ.១២០២)

| អ្នកប្តឹងត្រូវ៖ |
| --- |
| - សុំ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹងចំនួន ៣ច្បាប់ពី គឃ.សប |
| - បំពេញ និងផ្តល់ព័ត៌មានចាំបាច់លើ ទ.១២០២ គ្រប់ច្បាប់ រួចចុះហត្ថលេខា ឬផ្តិតមេដៃ |
| - យក ទ.១២០២ ទៅដាក់នៅ គធ.ខប តាមរយៈពេលកំណត់។ |

ព័ត៌មានចាំបាច់មួយចំនួនដែលត្រូវបំពេញក្នុង ទ.១២០២ រួមមាន៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- លក្ខណៈសម្គាល់នៃគឃ.សបឬនិងការិយាល័យបោះឆ្នោតនិងការិយាល័យរាប់សន្លឹកឆ្នោត
- ពេលវេលានៃការកើតឡើង និងប្រភេទនៃកំហុស ឬភាពមិនប្រក្រតី
- កម្មវត្ថុនៃការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ គឃ.សប
- ប្រសិនបើអាចធ្វើបានត្រូវបញ្ជាក់អំពីមាត្រានៃចប.តរឬប្រការនៃបន.តរដែលត្រូវបានរំលោភ
- មនុស្សដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តកំហុស ឬភាពមិនប្រក្រតីនេះ
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី ប្រសិនបើមាន
- សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងទៀត ប្រសិនបើមាន
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង ប្រសិនបើមាន។

### ៣. ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប

អ្នកប្តឹងត្រូវយកពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ច្បាប់ដែលបានបំពេញរួចទៅដាក់នៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធពាក្យបណ្តឹង។ ក្នុងរយៈពេលកំណត់នេះ បើ គធ.ខប មិនបានទទួលពាក្យបណ្តឹងចាត់ទុកថា គ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ឡើយ។

### ក. ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់

ប្រធាន គធ.ឃប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវ៖

- ណែនាំអ្នកប្តឹងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងពេលនៃការដាក់ពាក្យបណ្តឹង
- កត់ត្រាក្នុងកំណត់ហេតុ
- ក្នុងករណីដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតខាងលើ ប្រធាន គធ.ឃប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់មូលហេតុ
- ចុះហត្ថលេខាឈ្មោះ បោះត្រា គធ.ឃប និងចុះកាលបរិច្ឆេទលើ ទ.១២០២ គ្រប់ច្បាប់ និងត្រូវប្រើប្រាស់ដូចខាងក្រោម៖

ទ.១២០២ ចំនួន ៣ច្បាប់
  - ១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
  - ១ច្បាប់ ផ្ញើជូន គ.ជ.ប
  - ១ច្បាប់ រក្សាទុកជាឯកសារ

- ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ានឹងការបដិសេធរបស់ គធ.ឃប ទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលការបដិសេធ។

### ខ. ពាក្យបណ្តឹងដែលបានទទួលនៅ គធ.ឃប ក្រោយរយៈពេលកំណត់

ប្រធាន គធ.ឃប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវ៖

- ចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ
- ចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ឃប និងចុះកាលបរិច្ឆេទឱ្យបានច្បាស់លាស់ លើ ទ.១២០២ គ្រប់ច្បាប់ និងត្រូវប្រើប្រាស់ដូចខាងក្រោម៖

ទ.១២០២ ចំនួន ៣ច្បាប់
  - ១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
  - ១ច្បាប់ ផ្ញើជូន គ.ជ.ប

- ជម្រាបអ្នកប្តឹងថា ពាក្យបណ្តឹងរបស់គាត់បានដាក់នៅក្រោយរយៈពេលកំណត់ គធ.ឃប មិនអាចទទួលយកមកដោះស្រាយបានទេ។

### គ. ពាក្យបណ្តឹងដែលបានទទួលនៅ គធ.ឃប ក្នុងរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់គ្រប់គ្រាន់

ប្រធាន គធ.ឃប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវ៖

- ចុះកាលបរិច្ឆេទ ពេលវេលា រួចចុះហត្ថលេខា និងបោះត្រា គធ.ឃប លើ ទ.១២០២ ទាំង ៣ច្បាប់ និងត្រូវប្រើប្រាស់ដូចខាងក្រោម៖

ទ.១២០២ ចំនួន ៣ច្បាប់
  - ១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
  - ១ច្បាប់ បិទផ្សាយជាសាធារណៈនៅលគធ.ឃប
  - ១ច្បាប់ ទុកប្រើក្នុងការប្រជុំសម្រេច

- ជម្រាបអ្នកប្តឹង ឬតំណាងថា គធ.ឃប នឹងប្រជុំសម្រេចលើពាក្យបណ្តឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធនឹងបណ្តឹងនោះ
- រាយការណ៍អំពីករណីបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ខាងលើនេះជាបន្ទាន់ជូនប្រធាន គធ.ឃប ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានពាក្យបណ្តឹងនោះនៅចំពោះមុខតំណាងគណបក្សនយោបាយអ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាងពាក់ព័ន្ធ។

ចំណាំ៖

- គធ.ឃប ត្រូវសម្រេចលើពាក្យបណ្ដឹងដែលបានទទួលនៅ គធ.ឃប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង (ទ.១២០២)
- ប្រធាន គធ.ឃប អាចប្រគល់សិទ្ធិទទួលពាក្យបណ្ដឹងជូនដល់សមាជិកណាម្នាក់ ដោយត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវ។

## VI. ប្រតិបត្តិការរបស់ គធ.ឃប ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

បន្ទាប់ពីបានទទួលកញ្ចប់ «គ ពិសេស» និងស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្ដឹង» នៃឃុំ សង្កាត់មួយចំនួនហើយ គធ.ឃប ត្រូវចាត់វិធានការជាបណ្ដើរៗ ដូចខាងក្រោម៖

### ១. ការណែនាំក្រុមត្រួតពិនិត្យលទ្ធផល

- ឱ្យត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ដែលខ្លួនទទួលបន្ទុក តាមករណីនីមួយៗ ដោយឡែកពីគ្នា ទាំងឃុំ សង្កាត់គ្មានពាក្យបណ្ដឹង ទាំងឃុំ សង្កាត់មានពាក្យបណ្ដឹង
- ការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្តត្រូវធ្វើឱ្យបានរួចរាល់ឆាប់រហ័ស និងមិនឱ្យហួសរយៈពេល ៥ថ្ងៃឡើយ (គិតទាំងការបូកសរុបរបស់ក្រុមបូកសរុបលទ្ធផល) ដោយចាប់រាប់ពីថ្ងៃបានទទួលកញ្ចប់ «គ ពិសេស» និងស្បោង «គ» ឬ/និងស្បោង «គ មានពាក្យបណ្ដឹង»
- ប្រសិនបើចាប់ផ្ដើមត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយពុំត្រូវឈប់សម្រាកឡើយ ជាពិសេសចំពោះឃុំ សង្កាត់ណាដែលមានពាក្យបណ្ដឹងទាក់ទងនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរដែលតម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផលបើកកញ្ចប់សុវត្ថិភាព «ក» មួយ ឬច្រើន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈឯកសារបោះឆ្នោត និងសន្លឹកឆ្នោត
- ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ឃប ចំនួន២ ឬច្រើនក្រុមអាចត្រួតពិនិត្យលទ្ធផលជុំគ្នានៅក្នុងបន្ទប់តែមួយ តែនៅតាមតុដោយឡែកពីគ្នា ទៅតាមលទ្ធភាពជាក់ស្ដែងរបស់រាជធានី ខេត្ត។

### ២. ការកំណត់ និងការរៀបចំតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងអ្នកប្ដឹង ឬតំណាងត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលរាល់ដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ក្នុងរាជធានី ខេត្ត តាមការកំណត់ និងរៀបចំដូចខាងក្រោម៖

- គណបក្សនយោបាយនីមួយៗ នៅតាមឃុំ សង្កាត់ទាំងអស់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោតនីមួយៗ ក្នុងរាជធានី ខេត្ត ត្រូវជ្រើសតាំងឱ្យមានតំណាងពេញសិទ្ធិ និងតំណាងបម្រុងតាមចំនួនដែល គធ.ឃប បានកំណត់ ដែលអាចចូលរួមគ្រប់គ្រាន់ល្មម ក្នុងការសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ឃប

-តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍អាចផ្លាស់ប្តូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួន

-តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាង ត្រូវបានរៀបចំឱ្យស្ថិតនៅជិតល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។

ចំណាំ៖ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកប្តឹង ឬតំណាង អាចថតយករូបភាពនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផល និងបូកសរុបនៃការបោះឆ្នោតក្នុងរាជធានី ខេត្តបាន ប៉ុន្តែមិនត្រូវបង្កការអុកឡុក ឬរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

### ៣. ការកំណត់ និងការរៀបចំបន្ទប់សម្រាប់ក្រុមត្រួតពិនិត្យលទ្ធផល

គធ.ខប ត្រូវ៖

- កំណត់ចំនួនបន្ទប់ ដើម្បីតម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផលបំពេញការងារ
- រៀបចំតុ កៅអីឱ្យមានចំនួនគ្រប់គ្រាន់សម្រាប់ក្រុមនីមួយៗ និងកៅអីសម្រាប់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាង (ប្រសិនបើមាន)
- ណែនាំក្រុមត្រួតពិនិត្យឱ្យរៀបចំគំរូប្លង់ (ដូចគ្នានឹងគំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោត)
- ឱ្យមានសម្ភារៈ ឯកសារគ្រប់គ្រាន់សម្រាប់ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ។




## VII. ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់

ក្នុងករណីឃុំ សង្កាត់ណាគ្មានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សបប និងនៅ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្តដូចខាងក្រោម៖

**ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប**

- មិនត្រូវបើកកញ្ចប់សុវត្ថិភាព «ក» ណាមួយឡើយ
- គ្រាន់តែធ្វើការត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) តែប៉ុណ្ណោះព្រមទាំងផ្ទៀងផ្ទាត់បន្ថែម ជាមួយទិន្នន័យតួលេខលទ្ធផលដែលមានស្រាប់ក្នុងប្រព័ន្ធកុំព្យូទ័រ ឬនៅក្នុងហ្វ្លាស់រក្សាទុកទិន្នន័យ (USB Drive)។

## ១. ដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត

គធ.ខប ត្រូវធានាថា ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលគ្មានពាក្យបណ្ដឹងទាំងអស់ក្នុងរាជធានី ខេត្ត ត្រូវបានអនុវត្តម្ដងមួយឃុំ សង្កាត់ៗ ជាបន្តបន្ទាប់រហូតដល់អស់ឃុំ សង្កាត់គ្មានពាក្យបណ្ដឹង និងតាមលំដាប់លំដោយនៃនីតិវិធីដូចខាងក្រោម៖

**ប្រធានក្រុម៖**

-ត្រូវបង្គាប់ជំនួយការឱ្យនាំយកកញ្ចប់ "គ ពិសេស" នៃឃុំ សង្កាត់ដែលគ្មានពាក្យបណ្ដឹងម្ដងមួយៗ ពីកន្លែងរក្សាស្ដុកមកដាក់នៅលើតុចំពីមុខប្រធានក្រុម

-ត្រូវបើកកញ្ចប់ "គ ពិសេស" រួចដកយកស្រោមសំបុត្រដាក់ ទ.១១០៣ ទ.១១០៩ ស្រោមសំបុត្រដាក់ហ្វ្លាស់រក្សាទុកទិន្នន័យ (USB Drive) រក្សាទុកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងរាល់ស្រោមសំបុត្រដាក់ ទ.១១០១ ទ.១១០៨ ទ.១១០២ ដែលផ្ញើជូន គធ.ខប មកដាក់នៅលើតុ

-ត្រូវបញ្ជាប់ចូល (Login) ក្នុងប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត ដើម្បីទាញយកទិន្នន័យពីសេវបករណ៍ (Server) គ.ជ.ប ឬហ្វ្លាស់រក្សាទុកទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដើម្បីបង្ហាញលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឧបទស្សន៍កុំព្យូទ័រ (Monitor) ដើម្បីឱ្យភាគីពាក់ព័ន្ធដែលមានវត្តមានបានមើលឃើញទាំងអស់គ្នា

-ត្រូវចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះក្នុងប្រព័ន្ធកុំព្យូទ័រធៀបនឹង ទ.១១០៣ ទ.១១០៩

-ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់បន្ថែមជាមួយ ទ.១១០១ ទ.១១០៨ ទ.១១០២នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ (បើមានភាពមិនច្បាស់លាស់)

-ត្រូវធានាថា ទ.១១១៦គព ២ច្បាប់ដែលបានបោះពុម្ពត្រូវបានផ្ទៀងផ្ទាត់បានត្រឹមត្រូវជាមួយគ្នា និងមានបញ្ជាក់ឈ្មោះ និងលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ

**ប្រធានក្រុមៈ** →

- ត្រូវធានាថា ទ.១១១៦តព ទាំង ២ច្បាប់ មានបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោមៈ
  - តួលេខលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់មានភាពត្រឹមត្រូវ
  - គឃ.សប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប
  - ចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល
- ដាក់ក្នុងស្រោមសំបុត្រ ទ.១១១៦តព ទ.១១០៣ ទ.១១០៩ ជូនប្រធាន គធ.ខប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ដើម្បីពិនិត្យ និងសម្រេច។

**ចំណាំៈ**

បើ គឃ.សប មានកំហុសក្នុងការគណនាបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ប្រធានក្រុមត្រួតពិនិត្យត្រូវៈ

- បង្ហាញកំហុសនោះ និងការកែតម្រូវ ព្រមទាំងហេតុផលនៃការកែតម្រូវនោះនៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន
- ឆូតលើតួលេខដែលខុស តែមិនត្រូវធ្វើឱ្យបាត់លក្ខណៈសម្គាល់នៃតួលេខដើមទេ រួចសរសេរតួលេខថ្មីដែលត្រឹមត្រូវនៅក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង។

**២. ការពិនិត្យសម្រេចរបស់ គធ.ខប នៅលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងការប្រើប្រាស់**

ប្រសិនបើ គធ.ខប ពិនិត្យលើឯកសារដែលក្រុមត្រួតពិនិត្យលទ្ធផលបានប្រគល់ជូននោះឃើញថា មានភាពត្រឹមត្រូវហើយ ប្រធាន គធ.ខប ត្រូវៈ

- ចារយល់ព្រមចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើ ទ.១១១៦តព ទាំង ២ច្បាប់
- ដាក់បង្ហាញ ទ.១១១៦តព នៅចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍
- ទ.១១១៦តព ត្រូវប្រើប្រាស់ដូចខាងក្រោមៈ

ទ.១១១៦តព ចំនួន ២ច្បាប់ {
- ១ច្បាប់ រួមនឹងទ.១១០៣ +ទ.១១០៩ ច្រកចូលក្នុងស្រោមសំបុត្រដើម ហើយជូនក្រុមត្រួតពិនិត្យលទ្ធផលដាក់ក្នុងកញ្ចប់ "គ ពិសេស" ដើម្បីទុកជាឯកសារនៅ គធ.ខប
- ១ច្បាប់ ជូនក្រុមបូកសរុបលទ្ធផលដើម្បីបន្តអនុវត្ត។

៣. ការរៀបចំសម្ភារ ឯកសារឡើងវិញ

ប្រធាន គធ.ខប ត្រូវធានាថា៖

- រាល់ស្រោមសំបុត្រដាក់ ទ.១១០៣ និង ទ.១១០៩ ផ្ញើជូន គ.ជ.ប ដែលប្រធានក្រុមត្រួតពិនិត្យលទ្ធផលបានដកយកពីកញ្ចប់ «គ ពិសេស» នីមួយៗ និងបានប្រគល់ជូន គធ.ខប ត្រូវប្រមូលដាក់ឱ្យអស់ទៅក្នុងកញ្ចប់ «ឃ ពិសេស» ដែលត្រៀមបម្រុងជាស្រេចទុកផ្ញើជូន គ.ជ.ប
- ទ.១១១៦តព (១ច្បាប់) ទ.១១០៣ និង ទ.១១០៩ នៃឃុំ សង្កាត់នីមួយៗត្រូវបានច្រកចូលក្នុងស្រោមសំបុត្រដើម ហើយប្រមូលដាក់ក្នុងកញ្ចប់ «គ ពិសេស» រួចយកទៅរក្សាទុកនៅកន្លែងស្តុកវិញ ដែលត្រូវរក្សាទុកជាឯកសាររបស់ គធ.ខប
- ទ.១១០១ ទ.១១០៨ និង ទ.១១០២ នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ពាក់ព័ន្ធត្រូវបានច្រកចូលក្នុងស្រោមសំបុត្រដើម ហើយប្រមូលដាក់ចូលក្នុងកញ្ចប់ «គ ពិសេស» និងរក្សាទុកជាឯកសារនៅ គធ.ខប។

## VIII. ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ដាក់នៅ គឃ.សប និងនៅ គធ.ខប

ក្នុងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប ហើយពាក្យបណ្តឹងនោះត្រូវបានដាក់ប្តឹងបន្តនៅ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្ត ដូចខាងក្រោម៖

ក្រុមត្រួតពិនិត្យលទ្ធផលត្រូវ៖

- ត្រួតពិនិត្យជាមុននូវសេចក្តីសម្រេច (ទ.១២០៣) របស់ គឃ.សប លើពាក្យបណ្តឹងពាក់ព័ន្ធ
- ពិនិត្យរបាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមាន)
- ពិនិត្យលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធដែលត្រូវបានដាក់នៅ គធ.ខប
- លើកយោបល់ស្នើទៅ គធ.ខប ដើម្បីសម្រេចអនុញ្ញាតឱ្យបើក ឬមិនអនុញ្ញាតឱ្យបើកកញ្ចប់សុវត្ថិភាព «ក» នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

### ១. ករណីគ្មានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬពុំមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត

ក្នុងករណីនេះ គធ.ខប មិនចាំបាច់តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតឡើយ។ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តតាមនីតិវិធីទាំងស្រុង ដូចករណីឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ (សូមមើល និងអនុវត្តទាំងស្រុងតាមចំណុច VII)។

## ២. ករណីមានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោត

ក្នុងករណីនេះ គធ.ខប ត្រូវអនុញ្ញាតឱ្យបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។

### ក. នីតិវិធីនៃការបើកកញ្ចប់សុវត្ថិភាព «ក»

**ជាដំបូងក្រុមត្រួតពិនិត្យលទ្ធផលត្រូវ៖**

ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ដោយអនុវត្តដូចឃុំ សង្កាត់គ្មានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ (សូមមើល និងអនុវត្តតាមចំណុច១ ក្រោមចំណុច VII)។

**បន្ទាប់មកក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តបន្ថែមដោយ៖**

- ត្រូវបង្គាប់ជំនួយការឱ្យយកស្បោង «គ មានពាក្យបណ្ដឹង» នៃឃុំ សង្កាត់ពាក់ព័ន្ធពីបន្ទប់រក្សាស្តុក មកដាក់លើតុចំពីមុខខ្លួន
- កាត់សោឃ្លុំបើកស្បោង «គ មានពាក្យបណ្ដឹង» នោះ ដកយកស្បោង «ខ» ពាក់ព័ន្ធចេញមកក្រៅ
- បើកស្បោង «ខ» ដកយកកញ្ចប់សុវត្ថិភាព «ក» មកដាក់លើតុ
- បើកកញ្ចប់សុវត្ថិភាព «ក» ដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែលមានក្នុងកញ្ចប់សុវត្ថិភាព«ក» មកដាក់ដោយឡែកពីគ្នានៅលើតុខាងមុខគាត់
- ប្រគល់ ទ.១១០១ ទ.១១០៨ និង ទ.១១០២ ទៅឱ្យលេខាធិការសម្រាប់តាមដាន ពិនិត្យដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត
- បើកស្រោមសំបុត្រឬស្បោងប្លាស្ទិកម្តងមួយៗ ដើម្បីយកសម្ភារឯកសារបោះឆ្នោតមកត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ
- នៅពេលមាន ទ.១១០១ ទ.១១០៨ និង ទ.១១០២ ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ និងបញ្ហាជារួមដូចខាងក្រោម៖
  - ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
  - ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ

| | |
|---|---|
| បន្ទាប់មកក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តបន្ថែមដោយៈ | ▪ ពិនិត្យ និងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានមកបោះឆ្នោត<br>▪ ពិនិត្យផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះ ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលទទួលពីការិយាល័យបោះឆ្នោតមកវិញ<br>▪ រាប់ចំនួនសន្លឹកឆ្នោតខូច (ប្រសិនបើមាន)<br>▪ រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ<br>▪ ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ<br>▪ ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ<br>▪ ពិនិត្យមើលថា តើក្នុង ទ.១១០១ និង ទ.១១០២ មានចុះអំពីភាពមិនប្រក្រតីដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតដែរឬទេ<br>▪ ពិនិត្យមើលថា តើក្នុង ទ.១១០១ និង ទ.១១០២ មានភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខាជាសាក្សីដែរ ឬទេ។ |

**ចំណាំៈ**

- ក្នុងករណីចាំបាច់ គជ.ខប អាចធ្វើការស៊ើបអង្កេតស្រាវជ្រាវលើពាក្យបណ្ដឹង មុននឹងសម្រេចឱ្យបើក ឬមិនបើកកញ្ចប់សុវត្ថិភាព «ក»
- បើ គជ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព «ក» នៃការិយាល័យបោះឆ្នោតលើសពីមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តការងារនេះតាមលំនាំនីតិវិធីដដែល សម្រាប់កញ្ចប់សុវត្ថិភាព «ក» នីមួយៗ រហូតទាល់តែអស់កញ្ចប់សុវត្ថិភាព «ក» ដែលត្រូវបើក។

**ខ. របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត**

បន្ទាប់ពីបើកកញ្ចប់សុវត្ថិភាព «ក» នៃការិយាល័យបោះឆ្នោតណាមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរួច ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងៈ

- ធ្វើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតចំនួន ២ច្បាប់ ដែលត្រូវៈ
  - ▪ ចុះហត្ថលេខា ដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល
  - ▪ លើកយោបល់ស្នើសុំ គជ.ខប ពិនិត្យ សម្រេចតាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេសៈ
    - យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ឬ
    - យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ករណីរក

ឃើញកំហុសឆ្គងក្នុងការគណនាលេខ ឬ

• ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (សុំរាប់សន្លឹកឆ្នោតឡើងវិញ ឬសុំបោះឆ្នោតសាជាថ្មី)។

- ចារលើរបាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយបញ្ជាក់ខ្លឹមសារស្របទៅនឹងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល។

**គ. ឯកសារដែលត្រូវដាក់ជូន គធ.ខប ដើម្បីពិនិត្យសម្រេច**

ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវដាក់ជូន គធ.ខប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេសនូវ៖

- របាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលទាំង ២ច្បាប់
- សម្រង់សេចក្ដីសម្រេចរបស់ គឃ.សប លើពាក្យបណ្ដឹងពាក់ព័ន្ធ +របាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» (ប្រសិនបើមាន)
- ទ.១១១៦គព ចំនួន ២ ច្បាប់ + ទ.១១០៣ + ទ.១១០៩។

**ឃ. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតឡើងវិញ**

- ដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ទៅក្នុងស្បោងប្លាស្ទិក និងស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ចប់ដាក់ក្នុងកញ្ចប់សុវត្ថិភាព «ក» តាមលំនាំដើមវិញ
- ដាក់កញ្ចប់សុវត្ថិភាព «ក» ទៅក្នុងស្បោង «ខ» រួចចងភ្ជិត
- ដាក់ស្បោង «ខ» ចូលទៅក្នុងស្បោង «គ មានពាក្យបណ្ដឹង» តាមលំនាំដើម និងចាក់សោឃ្លុំមានលេខ រួចនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប។

**៣. ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់**

គធ.ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹង បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលបានត្រួតពិនិត្យលទ្ធផលនៃឃុំ សង្កាត់មានពាក្យបណ្ដឹងរួចរាល់ហើយ ដោយផ្អែកលើ៖

- របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតទាំង ២ច្បាប់របស់ក្រុមត្រួតពិនិត្យលទ្ធផល
- សម្រង់សេចក្ដីសម្រេចរបស់ គឃ.សប លើពាក្យបណ្ដឹងពាក់ព័ន្ធ (ប្រសិនបើមាន)
- របាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន)
- ទ.១១១៦គព ចំនួន ២ច្បាប់ + ទ.១១០៣ + ទ.១១០៩
- ពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែល គធ.ខប បានទទួល។

ក. ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់

ប្រធាន គធ.ខប ត្រូវ៖

- ចារយល់ព្រមលើ ទ.១១១៦តព ទាំង ២ច្បាប់របស់ក្រុមត្រួតពិនិត្យលទ្ធផល
- ចារយល់ព្រមលើរបាយការណ៍ទាំង ២ច្បាប់ ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប
- ចារយល់ព្រមលើសម្រង់សេចក្តីសម្រេចរបស់ គឃ.សប ដែលបានបដិសេធពាក្យបណ្តឹងពាក់ព័ន្ធ និងទទួលយកលទ្ធផលនៃការបោះឆ្នោត ឬចារបដិសេធលើសម្រង់សេចក្តីសម្រេចរបស់ គឃ.សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងពាក់ព័ន្ធ ដោយធ្វើការកែតម្រូវលទ្ធផលនៃការបោះឆ្នោត ឬបដិសេធលទ្ធផលនៃការបោះឆ្នោត
- ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ខប លើឯកសារខាងលើ
- ចាត់សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ឱ្យបំពេញ ទ.១២០៣ របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលត្រូវបដិសេធពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលដាក់នៅ គធ.ខប ដោយបញ្ជាក់ច្បាស់ពីមូលហេតុ
- ចុះហត្ថលេខាលើ ទ.១២០៣ ដោយសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត និងខ្លួនគាត់ចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប។ ទ.១២០៣ត្រូវប្រើប្រាស់ដូចខាងក្រោម៖

ទ.១២០៣
- ១ច្បាប់ ប្រគល់ជូនអ្នកប្តឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ
- ១ច្បាប់ រក្សាទុកជាឯកសារនៅ គធ.ខប។

- ជម្រាបអ្នកប្តឹង ឬតំណាងថា គាត់មានសិទ្ធិប្តឹងទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ខប
- ជូន ទ.១២០២ ចំនួន ៣ច្បាប់ ជូនអ្នកប្តឹង ឬតំណាង បើគាត់ស្នើសុំ
- ប្រគល់ជូនក្រុមបូកសរុបលទ្ធផលនៃ គធ.ខប ដើម្បីបន្តអនុវត្តភារកិច្ចរបស់ខ្លួននូវ

ទ.១១១៦គព ចំនួន ១ច្បាប់ + របាយការណ៍បើកកញ្ចប់សុវត្ថិភាព «ក» របស់ គធ.ឌប ចំនួន ១ច្បាប់ + សម្រង់សេចក្ដីសម្រេចរបស់ គឃ.សប ចំនួន ១ច្បាប់ (បើមាន) + សម្រង់សេចក្ដីសម្រេចរបស់ គធ.ឌប ចំនួន ១ច្បាប់

- ត្រៀមនូវ ទ.១១១៦គព ចំនួន ១ច្បាប់ + របាយការណ៍បើកកញ្ចប់សុវត្ថិភាព «ក» របស់ គធ.ឌប ចំនួន ១ច្បាប់ + សម្រង់សេចក្ដីសម្រេចរបស់ គឃ.សប ចំនួន ១ ច្បាប់ (បើមាន) + សម្រង់សេចក្ដីសម្រេចរបស់ គធ.ឌប ចំនួន ១ច្បាប់ ដាក់ក្នុងកញ្ចប់ «ឃ ពិសេស» សម្រាប់ផ្ញើជូន គ.ជ.ប។

**ខ. ប្រសិនបើ គធ.ឌប សម្រេចយល់ព្រមកែតម្រូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ក្នុងករណីរកឃើញកំហុសឆ្គងក្នុងការគណនាតួលេខ** ប្រធាន គធ.ឌប ត្រូវ៖

- ចារយល់ព្រមលើ ទ.១១១៦គព ទាំង ២ច្បាប់របស់ក្រុមត្រួតពិនិត្យលទ្ធផល
- ចារយល់ព្រមលើរបាយការណ៍ទាំង២ច្បាប់ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ឌប
